## ២-សេចក្តីសម្រេច

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ១៩៩៩

### សេចក្តីសម្រេចលេខ ៤៤ សសរ
### ស្តីពីការបង្កើតគណៈបញ្ជាការការពារ
### ពិធីកំទេចអាវុធនៅខេត្ត កំពង់ចាម

* * *

### រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ អនុក្រឹត្យលេខ ៣៨ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការគ្រប់គ្រង និងការត្រួតពិនិត្យការនាំចូល ការផលិត ការលក់ ការទិញដូរ ការចែកចាយ និងការប្រើប្រាស់អាវុធជាតិផ្ទុះគ្រប់ប្រភេទ
- បានឃើញ សេចក្តីសម្រេចលេខ ២៨ សសរ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតគណៈកម្មការដកហូតអាវុធជាតិផ្ទុះគ្រប់ប្រភេទ
- ពិនិត្យសំណូមពរចាំបាច់របស់រាជរដ្ឋាភិបាល

### សម្រេច

**ប្រការ ១ :** ត្រូវបានបង្កើតគណៈបញ្ជាការការពារពិធីកំទេចអាវុធ នៅខេត្តកំពង់ចាម រួមមានសមាសភាព ដូចខាងក្រោម ៖

| | | |
|---|---|---|
| ១- ឯកឧត្តម ឯក សំអាន | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ប្រធាន |
| ២- ឯកឧត្តម ឌៀខ នំ | អភិបាលខេត្តកំពង់ចាម | អនុប្រធាន |
| ៣- ឯ.ឧ.ឧ.ទោ ជឿន សុវណ្ណថា | មេបញ្ជាការយោធភូមិភាគទី ២ | សមាជិក |
| ៤- ឯកឧត្តម ខ្វាន់ សៀម | មេបញ្ជាការកងវិស្វកម្មក.យ.ខ.ភ | សមាជិក |
| ៥- ឯកឧត្តម ម៉ុន អ៊ុយ | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៦- ឯកឧត្តម យូ ស៊ុនឡុង | ប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ | សមាជិក |
| ៧- លោក ឧ. យុន ឈុន្នី | អនុប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់ | សមាជិក |

| | | | |
|---|---|---|---|
| ៨- | លោក ឧ. ម៉ៅ ចន្ទតារា | ប្រធានសេនាធិការអគ្គនាយកនគរបាល | សមាជិក |
| ៩- | លោក ឧ. សុខ ផល | ប្រធាននាយកដ្ឋានព័ត៌មានទូទៅ | សមាជិក |
| ១០- | លោក ឧ. លូ រ៉ាមីន | ប្រធាននាយកដ្ឋានប្រឆាំងភេរវកម្ម | សមាជិក |
| ១១- | លោក ហ៊ុល ផានី | ប្រធាននាយកដ្ឋានពិធីការ | សមាជិក |
| ១២- | លោក យ៉ាន តិសិដ្ឋ | | សមាជិក |
| ១៣- | លោក ជុំ សាគន្ធ | មេបញ្ជាការតំបន់ប្រតិបត្តិការសឹករង ខេត្តកំពង់ចាម | សមាជិក |
| ១៤- | លោក ទ៊ា សារិទ្ធ | មេបញ្ជាការកងរាជអាវុធហត្ថខេត្តកំពង់ចាម | សមាជិក |
| ១៥- | លោក វរ. សួន ឈាងលី | ស្នងការនគរបាល ខេត្តកំពង់ចាម | សមាជិក |

ប្រការ ២ : គណៈបញ្ជាការការពារពិធីកំទេចអាវុធមានភារកិច្ច ដូចតទៅ ៖

- រៀបចំចាត់ចែងពិធីឲ្យបានសមរម្យ ការពារសុវត្ថិភាពដល់ថ្នាក់ដឹកនាំជាន់ខ្ពស់របស់រាជរដ្ឋាភិបាល ភ្ញៀវកិត្តិយសជាតិនិងអន្តរជាតិ និងមហាជនចូលរួម
- ត្រួតពិនិត្យកុំឲ្យមានគ្រាប់រំសេវសល់ក្នុងអាវុធ ដែលត្រូវកំទេច រក្សាការពារ និងដឹកជញ្ជូនអាវុធ ដែលត្រូវកំទេចទៅដល់កន្លែងប្រារព្ធពិធី
- ចាត់ចែង អញ្ជើញ និងដោះស្រាយមធ្យោបាយដឹកជញ្ជូនភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិពីភ្នំពេញទៅខេត្តកំពង់ចាម
- រៀបចំសណ្តាប់ធ្នាប់សាធារណៈ ចរាចរទាំងនៅខាងក្នុង និងក្រៅបរិវេណកន្លែងប្រារព្ធពិធី
- ការពារសុវត្ថិភាព បង្ការទប់ស្កាត់ និងបង្ក្រាបទាន់ពេលវេលារាល់សកម្មភាពភេរវកម្ម ការបង្កចលាចលផ្សេងៗ ដល់ថ្នាក់ដឹកនាំជាន់ខ្ពស់របស់រាជរដ្ឋាភិបាល ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ សិស្ស និស្សិត និងមហាជនចូលរួម

ប្រការ ៣ : ក្នុងករណីចាំបាច់គណៈបញ្ជាការមានសិទ្ធិបង្កើតអនុគណៈបញ្ជាការ ដើម្បីជួយក្នុងការងារនេះ ។

ប្រការ ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អគ្គបញ្ជាការ ក.យ.ខ.ភ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ គណៈបញ្ជាការឯកភាពខេត្តកំពង់ចាម និងសាមីខ្លួន ត្រូវអនុវត្តសេចក្តីសំរេចនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខារហូតដល់ចប់ពិធីជាស្ថាពរ ។

នាយករដ្ឋមន្ត្រីស្តីទី

ហត្ថលេខា និង ត្រា

ស ខេង

★★★